[ ៣៩៥ ] ធម៌មិនមែនប្រកបដោយសុខវេទនា មិនមែនជាកុសល អា-ស្រ័យនូវធម៌ មិនមែនប្រកបដោយទុក្ខវេទនា មិនមែនជាកុសលផង មិនមែនប្រកបដោយអទុក្ខមសុខវេទនា មិនមែនជាកុសលផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនប្រកបដោយទុក្ខវេទនា មិនមែនជាកុសល អាស្រ័យនូវធម៌ មិនមែនប្រកបដោយទុក្ខវេទនា មិនមែនជាកុសលផង មិនមែនប្រកបដោយអទុក្ខមសុខវេទនា មិនមែនជាកុសលផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនប្រកបដោយអទុក្ខមសុខវេទនា មិនមែនជាកុសល អាស្រ័យនូវធម៌មិនមែនប្រកបដោយទុក្ខវេទនា មិនមែនជាកុសលផង មិនមែនប្រកបដោយអទុក្ខមសុខវេទនា មិនមែនជាកុសលផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៣៩៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៤៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៤៩ ។

[ ៣៩៧ ] ធម៌មិនមែនប្រកបដោយសុខវេទនា មិនមែនជាអកុសល អាស្រ័យនូវធម៌ មិនមែនប្រកបដោយសុខវេទនា មិនមែនជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៣៩៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៤៩ ។

[ ៣៩៩ ] ធម៌មិនមែនប្រកបដោយសុខវេទនា មិនមែនជាអព្យាកតៈ

អាស្រ័យនូវធម៌មិនមែនប្រកបដោយសុខវេទនា មិនមែនជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៤០០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៤៨ សេចក្ដីពិស្ដារ មានគ្រប់បច្ច័យទាំងអស់ ។

## ឯវេទនាត្តិកឯវិបាកត្តិកៈ

[ ៤០១ ] ធម៌មិនមែនប្រកបដោយសុខវេទនា មិនមែនជាវិបាក អាស្រ័យនូវធម៌ មិនមែនប្រកបដោយសុខវេទនា មិនមែនជាវិបាក ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៤០២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៤៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៤៩ សេចក្ដីបំប្រួញ ។

## ឯវិបាកត្តិកឯកុសលត្តិកៈ

[ ៤០៣ ] អាស្រ័យនូវធម៌ មិនមែនជាវិបាក មិនមែនជាកុសល... អាស្រ័យនូវធម៌ មិនមែនមានវិបាកធម៌ជាប្រក្រតី មិនមែនជាកុសល... អាស្រ័យនូវធម៌ មិនមែនជាមិនមែនវិបាក និងមិនមែនមានវិបាកធម៌ជាប្រក្រតី មិនមែនជាកុសល... ។

## នឧបាទិន្នុបាទានិយត្តិកនកុសលត្តិកៈ

[ ៤០៤ ] អាស្រ័យនូវធម៌ដែលមិនមែនកម្មប្រកបដោយកិលេស ( មានតណ្ហាជាដើម ) កាន់យក និងជាប្រយោជន៍ដល់ឧបាទាន មិនមែនជាកុសល... អាស្រ័យនូវធម៌ដែលមិនមែនកម្មប្រកបដោយកិលេសមិនកាន់យកតែជាប្រយោជន៍ដល់ឧបាទាន មិនមែនជាកុសល... អាស្រ័យនូវធម៌ ដែលមិនមែនកម្មប្រកបដោយកិលេសមិនកាន់យកទាំងមិនជាប្រយោជន៍ដល់ឧបាទាន មិនមែនជាកុសល... ។

## នសង្កិលិដ្ឋសង្កិលេសិកត្តិកនកុសលត្តិកៈ

[ ៤០៥ ] អាស្រ័យនូវធម៌ ដែលមិនមែនសៅហ្មងនិងគួរដល់សេចក្តីសៅហ្មង មិនមែនជាកុសល... អាស្រ័យនូវធម៌ដែលមិនមែនជាមិនសៅហ្មងតែគួរដល់សេចក្តីសៅហ្មង មិនមែនជាកុសល... អាស្រ័យនូវធម៌ដែលមិនមែនជាមិនសៅហ្មង ទាំងមិនគួរដល់សេចក្តីសៅហ្មង មិនមែនជាកុសល... ។

## នវិតក្កត្តិកនកុសលត្តិកៈ

[ ៤០៦ ] អាស្រ័យនូវធម៌ មិនមែនប្រព្រឹត្តទៅជាមួយនឹងវិតក្កៈនិងប្រព្រឹត្តទៅជាមួយនឹងវិចារៈ មិនមែនជាកុសល... អាស្រ័យនូវធម៌ មិនមែនជាមិនមានវិតក្កៈ មានត្រឹមតែវិចារៈ មិនមែនជាកុសល... អាស្រ័យនូវធម៌

មិនមែនជាមិនមានវិតក្កៈ និងមិនមានវិចារៈ មិនមែនជាកុសល... ។

## នបីតិត្តិក នកុសលត្តិកៈ

[ ៤០៧ ] អាស្រ័យនូវធម៌មិនមែនប្រកបដោយបីតិ មិនមែនជាកុសល... អាស្រ័យនូវធម៌ មិនមែនប្រកបដោយសុខ មិនមែនជាកុសល... អាស្រ័យនូវធម៌ មិនមែនប្រកបដោយឧបេក្ខា មិនមែនជាកុសល... ។

## នទស្សនត្តិក នកុសលត្តិកៈ

[ ៤០៨ ] អាស្រ័យនូវធម៌មិនមែនត្រូវលះដោយទស្សនៈ មិនមែនជាកុសល... អាស្រ័យនូវធម៌មិនមែនត្រូវលះដោយភាវនា មិនមែនជាកុសល... អាស្រ័យនូវធម៌ មិនមែនជាមិនមែនត្រូវលះដោយទស្សនៈនិង មិនមែនត្រូវលះដោយភាវនា មិនមែនជាកុសល... ។

## នទស្សនេនបហាតព្វហេតុកត្តិកនកុសលត្តិកៈ

[ ៤០៩ ] អាស្រ័យនូវធម៌មានហេតុដែលមិនមែនត្រូវលះដោយទស្សនៈ មិនមែនជាកុសល... អាស្រ័យនូវធម៌ មានហេតុដែលមិនមែនត្រូវលះដោយភាវនា មិនមែនជាកុសល... អាស្រ័យនូវធម៌មានហេតុដែលមិនមែនជាមិន

មែនត្រូវលះដោយទស្សនៈ និងមិនមែនត្រូវលះដោយភាវនា មិនមែនជាកុសល... ។

## ឆអាចយគាមិត្តិកឆកុសលត្តិកៈ

[ ៤១០ ] អាស្រ័យនូវធម៌មិនមែនដល់នូវការសន្សំកពូនឡើង ( ដោយកម្មកិលេស ) មិនមែនជាកុសល... អាស្រ័យនូវធម៌ មិនមែនជាមិនដល់នូវការសន្សំកពូនឡើង មិនមែនជាកុសល... អាស្រ័យនូវធម៌ មិនមែនជាមិនមែនដល់នូវការសន្សំកពូនឡើង ទាំងមិនមែនជាមិនដល់នូវការសន្សំកពូនឡើង មិនមែនជាកុសល... ។

## ឆសេក្ខត្តិកឆកុសលត្តិកៈ

[ ៤១១ ] អាស្រ័យនូវធម៌ មិនមែនជាសេក្ខៈ មិនមែនជាកុសល... អាស្រ័យនូវធម៌ មិនមែនជាអសេក្ខៈ មិនមែនជាកុសល... អាស្រ័យនូវធម៌ មិនមែនជានេវសេក្ខានាសេក្ខៈ មិនមែនជាកុសល... ។

## ឆបរិត្តត្តិកឆកុសលត្តិកៈ

[ ៤១២ ] អាស្រ័យនូវធម៌ មិនមែនជាសភាពតូចថោករ មិនមែនជា

កុសល... អាស្រ័យនូវធម៌ មិនមែនដល់នូវសភាពធំ មិនមែនជាកុសល... អាស្រ័យនូវធម៌ មិនមែនមានប្រមាណមិនបាន មិនមែនជាកុសល... ។

## នបរិត្តារម្មណត្តិកនកុសលត្តិកៈ

[ ៤១៣ ] អាស្រ័យនូវធម៌ មិនមែនមានអារម្មណ៍តូចឆ្មារ មិនមែនជាកុសល... អាស្រ័យនូវធម៌ មិនមែនមានអារម្មណ៍ដល់នូវសភាពធំ មិនមែនជាកុសល... អាស្រ័យនូវធម៌ មិនមែនមានអារម្មណ៍ប្រមាណមិនបាន មិនមែនជាកុសល... ។

## នហីនត្តិកនកុសលត្តិកៈ

[ ៤១៤ ] អាស្រ័យនូវធម៌ មិនមែនជាថោកទាប មិនមែនជាកុសល... អាស្រ័យនូវធម៌ មិនមែនជាកណ្តាល មិនមែនជាកុសល... អាស្រ័យនូវធម៌មិនមែនឧត្តម មិនមែនជាកុសល... ។

## នមិច្ឆត្តត្តិកនកុសលត្តិកៈ

[ ៤១៥ ] អាស្រ័យនូវធម៌ មិនមែនជាសភាពខុសនិងទៀង មិនមែនជាកុសល... អាស្រ័យនូវធម៌ មិនមែនជាសភាពត្រូវនិងទៀង មិនមែនជា

កុសល... អាស្រ័យនូវធម៌ មិនមែនជាមិនទៀង មិនមែនជាកុសល... ។

## ធម្មគ្គារម្មណត្តិកធកុសលត្តិកៈ

[ ៤១៦ ] អាស្រ័យនូវធម៌ មិនមែនមានមគ្គជាអារម្មណ៍ មិនមែនជាកុសល... អាស្រ័យនូវធម៌ មិនមែនមានមគ្គជាហេតុ មិនមែនជាកុសល... អាស្រ័យនូវធម៌ មិនមែនមានមគ្គជាអធិបតិ មិនមែនជាកុសល... ។

## ធឧប្បន្នត្តិកធកុសលត្តិកៈ

[ ៤១៧ ] អាស្រ័យនូវធម៌មិនមែនជាមិនទាន់កើតឡើងហើយ មិនមែនជាកុសល... អាស្រ័យនូវធម៌ មិនមែនកើតឡើង មិនមែនជាកុសល... ។

## ធអតីតត្តិកធកុសលត្តិកៈ

[ ៤១៨ ] អាស្រ័យនូវធម៌មិនមែនជាអតីត មិនមែនជាកុសល... អាស្រ័យនូវធម៌ មិនមែនជាអនាគត មិនមែនជាកុសល... ។

## ធអតីតារម្មណត្តិកធកុសលត្តិកៈ

[ ៤១៩ ] អាស្រ័យនូវធម៌ មិនមែនមានអារម្មណ៍ជាអតីត មិនមែនជា

កុសល... អាស្រ័យនូវធម៌ មិនមែនមានអារម្មណ៍ជាអនាគត មិនមែនជាកុ-សល... អាស្រ័យនូវធម៌ មិនមែនមានអារម្មណ៍ជាបច្ចុប្បន្ន មិនមែនជាកុ-សល... ។

## នអជ្ឈត្តត្តិកនកុសលត្តិកៈ

[ ៤២០ ] អាស្រ័យនូវធម៌ មិនមែនជាខាងក្នុង មិនមែនជាកុសល... អាស្រ័យនូវធម៌ មិនមែនជាខាងក្រៅ មិនមែនជាកុសល... ។

## នអជ្ឈត្តារម្មណត្តិកនកុសលត្តិកៈ

[ ៤២១ ] អាស្រ័យនូវធម៌ មិនមែនមានអារម្មណ៍ខាងក្នុង មិនមែនជាកុសល... អាស្រ័យនូវធម៌ មិនមែនមានអារម្មណ៍ខាងក្រៅ មិនមែនជាកុ-សល... ។

## នសនិទស្សនត្តិកនកុសលត្តិកៈ

[ ៤២២ ] ធម៌មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនជាកុសល អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនជាកុសល ទើបកើតឡើង ព្រោះហេ-

តុប្បច្ច័យ ធម៌មិនមែនជាមិនមានការឃើញ តែប្រកបដោយការប៉ះពាល់ មិនមែនជាកុសល អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ មិនមែនជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនជាមិនមានការឃើញ និងមិនមានការប៉ះពាល់ មិនមែនជាកុសល អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ មិនមែនជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៦ ។ ធម៌មិនមែនជាមិនមានការឃើញ តែប្រកបដោយការប៉ះពាល់ មិនមែនជាកុសល អាស្រ័យនូវធម៌ មិនមែនជាមិនមានការឃើញ តែប្រកបដោយការប៉ះពាល់ មិនមែនជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ មិនមែនជាកុសល អាស្រ័យនូវធម៌ មិនមែនជាមិនមានការឃើញ តែប្រកបដោយការប៉ះពាល់ មិនមែនជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនជាមិនមានការឃើញ និងមិនមានការប៉ះពាល់ មិនមែនជាកុសល អាស្រ័យនូវធម៌ មិនមែនជាមិនមានការឃើញ តែប្រកបដោយការប៉ះពាល់ មិនមែនជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៦ ។ ធម៌មិនមែនជាមិនមានការឃើញ និងមិនមានការប៉ះពាល់ មិនមែនជាកុសល អាស្រ័យនូវធម៌មិនមែនជាមិនមានការឃើញ និងមិនមានការប៉ះពាល់ មិនមែនជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៦ ។ ធម៌មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ មិនមែនជាកុសល អាស្រ័យនូវធម៌មិន

មែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ មិនមែនជាកុសល ផង មិនមែនជាមិនមានការឃើញនិងមិនមានការប៉ះពាល់ មិនមែនជាកុសល ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៦ ។ ធម៌មិនមែនប្រកប ដោយការឃើញនិងប្រកបដោយការប៉ះពាល់ មិនមែនជាកុសល អាស្រ័យ នូវធម៌មិនមែនជាមិនមានការឃើញ តែប្រកបដោយការប៉ះពាល់ មិនមែនជា កុសលផង មិនមែនជាមិនមានការឃើញនិងមិនមានការប៉ះពាល់ មិនមែនជា កុសលផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៦ ។

[ ៤២៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣០ ក្នុងអារម្មណប្បច្ច័យ មាន វារៈ ៩ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

[ ៤២៤ ] ធម៌មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះ ពាល់ មិនមែនជាអកុសល អាស្រ័យនូវធម៌មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនជាអកុសល ទើបកើតឡើង ព្រោះ ហេតុប្បច្ច័យ ។

[ ៤២៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣០ ក្នុងអារម្មណប្បច្ច័យ មាន វារៈ ៩ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

[ ៤២៦ ] ធម៌មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះ ពាល់ មិនមែនជាអព្យាកតៈ អាស្រ័យនូវធម៌មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនជាអព្យាកតៈ ទើបកើតឡើង ព្រោះ ហេតុប្បច្ច័យ ។

[ ៤២៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ។

## ផស្សនិស្សយទុកវេទនាត្តិកៈ

[ ៤២៨ ] អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ មិនមែនប្រកបដោយសុខវេទនា... មានវារៈ ៣០ ។ អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ មិនមែនប្រកបដោយសុខវេទនា... មានវារៈ ៣០ ។ អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនប្រកបដោយទុក្ខវេទនា... មានវារៈ ៣០ ។ អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ មិនមែនប្រកបដោយអទុក្ខមសុខវេទនា... មានវារៈ ៣០ ។

## ផស្សនិស្សយទុកវិបាកត្តិកៈ

[ ៤២៩ ] អាស្រ័យនូវធម៌ មិនមែនជាវិបាក មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់... មានវារៈ ៣០ ។ អាស្រ័យនូវធម៌ មិនមែនមានវិបាកជាប្រក្រតី មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់... មានវារៈ ៣០ ។ អាស្រ័យនូវធម៌ មិនមែនជាមិនមែនវិបាក

និងមិនមែនមានវិបាកជាប្រក្រតី មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់... មានវារៈ ៩ ។

## នសនិទស្សនត្តិកនឧបាទិន្នុបាទានិយត្តិកៈ

[ ៤៣០ ] អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនដែលកម្មប្រកបដោយកិលេស ( មានតណ្ហាជាដើម ) កាន់យកទាំងជាប្រយោជន៍ដល់ឧបាទាន... មានវារៈ ៣០ ។ អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនដែលកម្មប្រកបដោយកិលេស មិនកាន់យក តែជាប្រយោជន៍ដល់ឧបាទាន... មានវារៈ ៣០ ។ អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនដែលកម្មប្រកបដោយកិលេស មិនកាន់យក ទាំងមិនជាប្រយោជន៍ដល់ឧបាទាន... មានវារៈ ៣០ ។

## នសនិទស្សនត្តិកនសង្កិលិដ្ឋសង្កិលេសិកត្តិកៈ

[ ៤៣១ ] អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ មិនមែនសៅហ្មង ទាំងគួរដល់សេចក្ដីសៅហ្មង... អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនជាមិនសៅហ្មង តែគួរដល់សេចក្ដីសៅហ្មង... អាស្រ័យនូវធម៌មិន

មែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ មិនមែនជាមិនសៅ-ហ្មង ទាំងមិនគួរដល់សេចក្ដីសៅហ្មង... ។

## នសនិនស្បនត្តិកនវិតក្កត្តិកៈ

[ ៤៣២ ] អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ មិនមែនប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ទាំងប្រព្រឹត្តទៅជាមួយនឹងវិចារៈ... អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនជាមិនមានវិតក្កៈ មានត្រឹមតែវិចារៈ ... អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ មិនមែនជាមិនមានវិតក្កៈទាំងមិនមានវិចារៈ... ។

## នសនិនស្បនត្តិកនបីតិត្តិកៈ

[ ៤៣៣ ] អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនប្រកបដោយបីតិ... អាស្រ័យនូវធម៌មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនប្រកបដោយសុខ... អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ មិនមែនប្រកបដោយឧបេក្ខា... ។

## នសនិនស្សនត្តិកនទស្សនត្តិកៈ

[ ៤៣៤ ] អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនត្រូវលះដោយទស្សនៈ... អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនត្រូវលះដោយភាវនា... អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនជាមិនមែនត្រូវលះដោយទស្សនៈ និងមិនមែនត្រូវលះដោយភាវនា... ។

## នសនិនស្សនត្តិកនទស្សនេនបហាតព្វហេតុកត្តិកៈ

[ ៤៣៥ ] អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មានហេតុដែលមិនមែនត្រូវលះដោយទស្សនៈ... អាស្រ័យនូវធម៌មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ មានហេតុដែលមិនមែនត្រូវលះដោយភាវនា... អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ មានហេតុដែលមិនមែនជាមិនត្រូវលះដោយទស្សនៈ និងមិនមែនត្រូវលះដោយភាវនា... ។

## នសនិនស្សនត្តិកនអាចយគាមិត្តិកៈ

[ ៤៣៦ ] អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញ និងប្រកប

ដោយការប៉ះពាល់ មិនមែនដល់នូវការសន្សំកពូនឡើង... អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនជាមិនដល់នូវការសន្សំកពូនឡើង... អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនជាមិនដល់នូវការសន្សំកពូនឡើង មិនមែនជាមិនដល់នូវការសន្សំកពូនឡើង... ។

## នសនិទស្សនត្តិកនសេក្ខត្តិកៈ

[ ៤៣៧ ] អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនជាសេក្ខៈ... អាស្រ័យនូវធម៌មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ មិនមែនជាអសេក្ខៈ... អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនជាមិនមែនជាសេក្ខៈ ទាំងមិនមែនជាអសេក្ខៈ... ។

## នសនិទស្សនត្តិកនបរិត្តត្តិកៈ

[ ៤៣៨ ] អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនជាសភាពតូចឆ្មារ... អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនដល់នូវសភាពធំ... អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះ

ពាល់ មិនមែនមានប្រមាណមិនបាន... ។

## ធសធិធស្សនត្តិកធបរិត្តារម្មណត្តិកៈ

[ ៤៣៩ ] អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនមានអារម្មណ៍តូចឆ្មារ... អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ មិនមែនមានអារម្មណ៍ដល់នូវសភាពធំ... អាស្រ័យនូវធម៌មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ មិនមែនមានអារម្មណ៍ប្រមាណមិនបាន... ។

## ធសធិធស្សនត្តិកធហីនត្តិកៈ

[ ៤៤០ ] អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនជាថោកទាប... អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនជាកណ្តាល... អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនជាឧត្តម... ។

## នសនិនស្សនត្តិកនមិច្ឆត្តត្តិកៈ

[ ៤៤១ ] អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនជាសភាពខុសនិងទៀង... អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនជាសភាពត្រូវនិងទៀង... អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ មិនមែនជាសភាពមិនទៀង... ។

## នសនិនស្សនត្តិកនមគ្គារម្មណត្តិកៈ

[ ៤៤២ ] អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនមានមគ្គជាអារម្មណ៍... អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនមានមគ្គជាហេតុ... អាស្រ័យនូវធម៌មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ មិនមែនមានមគ្គជាអធិបតិ... ។

## នសនិនស្សនត្តិកនឧប្បន្នត្តិកៈ

[ ៤៤៣ ] អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនជាមិនទាន់កើតឡើងហើយ... អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនកើត

ឡើង... ។

# ឆសនិធស្សនត្តិកនអតីតត្តិកៈ

[ ៤៤៤ ] អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនជាអតីត... អាស្រ័យនូវធម៌មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនជាអនាគត... ។

# ឆសនិធស្សនត្តិកនអតីតារម្មណត្តិកៈ

[ ៤៤៥ ] អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនមានអារម្មណ៍ជាអតីតៈ... អាស្រ័យនូវធម៌មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មានអារម្មណ៍ជាអនាគត... អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ មិនមែនមានអារម្មណ៍ជាបច្ចុប្បន្ន... ។

# ឆសនិធស្សនត្តិកនអជ្ឈត្តត្តិកៈ

[ ៤៤៦ ] អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនប្រព្រឹត្តទៅខាងក្នុង... អាស្រ័យនូវធម៌ មិនមែន

ប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ មិនមែនប្រព្រឹត្តទៅខាងក្រៅ... ។

# ទស្សនសម្បយុត្តិកទុកអជ្ឈត្តារម្មណត្តិកៈ

[ ៤៤៧ ] ធម៌មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនមានអារម្មណ៍ជាខាងក្នុង អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនមានអារម្មណ៍ជាខាងក្នុង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនជាមិនមានការឃើញតែប្រកបដោយការប៉ះពាល់ មិនមែនមានអារម្មណ៍ជាខាងក្នុង អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនមានអារម្មណ៍ជាខាងក្នុង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៤៤៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣០ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣០ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

[ ៤៤៩ ] ធម៌មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនមានអារម្មណ៍ជាខាងក្រៅ អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនមានអារម្មណ៍ជាខាងក្រៅ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនជាមិនមានការឃើញតែប្រកបដោយការប៉ះពាល់ មិនមែនមានអារម្មណ៍ជាខាងក្រៅ អាស្រ័យនូវ

ធម៌មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ មិនមែនមានអារម្មណ៍ជាខាងក្រៅ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនជាមិនមានការឃើញ ទាំងមិនមានការប៉ះពាល់ មិនមែនមានអារម្មណ៍ជាខាងក្រៅ អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ មិនមែនមានអារម្មណ៍ជាខាងក្រៅ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៦ ។

[ ៤៥០ ] ធម៌មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនមានអារម្មណ៍ជាខាងក្រៅ អាស្រ័យនូវធម៌ មិនមែនជាមិនមានការឃើញតែប្រកបដោយការប៉ះពាល់ មិនមែនមានអារម្មណ៍ជាខាងក្រៅ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៦ ។

[ ៤៥១ ] ធម៌មិនមែនជាមិនមានការឃើញ ទាំងមិនមានការប៉ះពាល់ មិនមែនមានអារម្មណ៍ជាខាងក្រៅ អាស្រ័យនូវធម៌ មិនមែនជាមិនមានការឃើញទាំងមិនមានការប៉ះពាល់ មិនមែនមានអារម្មណ៍ជាខាងក្រៅ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៦ ។

[ ៤៥២ ] ធម៌មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនមានអារម្មណ៍ជាខាងក្រៅ អាស្រ័យនូវធម៌ មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនមានអារម្មណ៍ជាខាងក្រៅផង មិនមែនជាមិនមានការឃើញទាំងមិនមានការប៉ះពាល់ មិនមែនមានអារម្មណ៍ជាខាងក្រៅផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៦ ។

[ ៤៥៣ ] ធម៌មិនមែនប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ មិនមែនមានអារម្មណ៍ជាខាងក្រៅ អាស្រ័យនូវធម៌ មិនមែនជាមិនមានការឃើញតែប្រកបដោយការប៉ះពាល់ មិនមែនមានអារម្មណ៍ជាខាងក្រៅផង មិនមែនជាមិនមានការឃើញ ទាំងមិនមានការប៉ះពាល់ មិនមែនមានអារម្មណ៍ជាខាងក្រៅផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៦ ។

[ ៤៥៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣០ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣០ ។

សេចក្តីពិស្តារមានក្នុងសហជាតវារៈផង ក្នុងបច្ចយវារៈផង ក្នុងនិស្សយវារៈផង ក្នុងសំសដ្ឋវារៈផង ក្នុងសម្បយុត្តវារៈផង ក្នុងបញ្ហាវារៈផង ។

## ចប់ បច្ចនីយត្តិកប្បដ្ឋាន ។

# បច្ចនីយទុកទុកប្បដ្ឋាន

## នហេតុទុកនសហេតុកទុកៈ

[ ៤៥៥ ] ធម៌មិនមែនជាហេតុ មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៤៥៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៤៥៧ ] ធម៌មិនមែនជាហេតុ មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។

[ ៤៥៨ ] ធម៌មិនមែនជាហេតុ មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ ។

[ ៤៥៩ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ។

[ ៤៦០ ] ធម៌មិនមែនជាហេតុ មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ ជាបច្ច័យនៃធម៌ មិនមែនជាហេតុ មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ ដោយហេតុប្បច្ច័យ ។

[ ៤៦១ ] ធម៌មិនមែនជាហេតុ មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ ជា

បច្ច័យនៃធម៌ មិនមែនជាហេតុ មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ ដោយអារម្មណប្បច្ច័យ ធម៌មិនមែនជាហេតុ មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ ជាបច្ច័យនៃធម៌ មិនមែនជាមិនមែនជាហេតុ មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ ដោយអារម្មណប្បច្ច័យ ។

[ ៤៦២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ៤ ។

[ ៤៦៣ ] ធម៌មិនមែនជាហេតុ មិនមែនជាមិនមានហេតុ អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនជាមិនមានហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនជាមិនមែនជាហេតុ មិនមែនជាមិនមានហេតុ អាស្រ័យនូវធម៌មិនមែនជាហេតុ មិនមែនជាមិនមានហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនជាហេតុ មិនមែនជាមិនមានហេតុក្តី មិនមែនជាមិនមែនជាហេតុ មិនមែនជាមិនមានហេតុក្តី អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនជាមិនមានហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៤៦៤ ] ធម៌មិនមែនជាមិនមែនជាហេតុ មិនមែនជាមិនមានហេតុ អាស្រ័យនូវធម៌ មិនមែនជាមិនមែនជាហេតុ មិនមែនជាមិនមានហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនជាហេតុ មិនមែនជាមិនមានហេតុ អាស្រ័យនូវធម៌ មិនមែនជាមិនមែនជាហេតុ មិនមែនជាមិនមានហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនជាហេតុ មិនមែនជាមិនមានហេតុក្តី មិនមែនជាមិនមែនជាហេតុ មិនមែនជាមិនមានហេតុក្តី អាស្រ័យនូវធម៌

មិនមែនជាមិនមែនជាហេតុ មិនមែនជាមិនមានហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៤៦៥ ] ធម៌មិនមែនជាហេតុ មិនមែនជាមិនមានហេតុ អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនជាមិនមានហេតុផង មិនមែនជាមិនមែនជាហេតុ មិនមែនជាមិនមានហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនជាមិនមែនជាហេតុ មិនមែនជាមិនមានហេតុ អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនជាមិនមានហេតុផង មិនមែនជាមិនមែនជាហេតុ មិនមែនជាមិនមានហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនជាហេតុ មិនមែនជាមិនមានហេតុក្តី មិនមែនជាមិនមែនជាហេតុ មិនមែនជាមិនមានហេតុក្តី អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនជាមិនមានហេតុផង មិនមែនជាមិនមែនជាហេតុ មិនមែនជាមិនមានហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៤៦៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ។

## នហេតុទុកនហេតុសម្បយុត្តទុកៈ

[ ៤៦៧ ] ធម៌មិនមែនជាហេតុ មិនមែនប្រកបដោយហេតុ អាស្រ័យ

នូវធម៌ មិនមែនជាហេតុ មិនមែនប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌មិនមែនជាហេតុ មិនមែនប្រាសចាកហេតុ អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនប្រាសចាកហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌មិនមែនជាមិនមែនជាហេតុ មិនមែនប្រាសចាកហេតុ អាស្រ័យនូវធម៌ មិនមែនជាមិនមែនជាហេតុ មិនមែនប្រាសចាកហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៤៦៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ សេចក្ដីពិស្ដារ មានក្នុងបច្ច័យទាំងអស់ ។

## នហេតុទុកនហេតុសហេតុកទុកៈ

[ ៤៦៩ ] ធម៌មិនមែនជាហេតុ មិនមែនជាហេតុទាំងមិនមែនជាមិនមានហេតុ អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនជាហេតុទាំងមិនមែនជាមិនមានហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ក្នុងបញ្ហាវារៈ មានវារៈតែ ១ ជាកំណត់ ។ ធម៌មិនមែនជាមិនមែនជាហេតុ មិនមែនជាមិនមានហេតុ ទាំងមិនមែនជាមិនមែនជាហេតុ អាស្រ័យនូវធម៌ មិនមែនជាមិនមែនជាហេតុ មិនមែនជាមិនមានហេតុ ទាំងមិនមែនជាមិនមែនហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

## នហេតុទុកនហេតុហេតុសម្បយុត្តទុកៈ

[ ៤៧០ ] ធម៌មិនមែនជាហេតុ មិនមែនជាហេតុទាំងមិនមែនប្រាសចាកហេតុ អាស្រ័យនូវធម៌មិនមែនជាហេតុ មិនមែនជាហេតុទាំងមិនមែនប្រាសចាកហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនជាមិនមែនជាហេតុ មិនមែនប្រាសចាកហេតុ ទាំងមិនមែនជាមិនមែនជាហេតុ អាស្រ័យនូវធម៌មិនមែនជាមិនមែនជាហេតុ មិនមែនប្រាសចាកហេតុ ទាំងមិនមែនជាមិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

## នហេតុទុកនហេតុនសហេតុកទុកៈ

[ ៤៧១ ] ធម៌មិនមែនជាហេតុ មិនមែនជាហេតុនិងមិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនជាហេតុនិងមិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌មិនមែនជាហេតុ មិនមែនជាហេតុនិងមិនមែនជាមិនមានហេតុ អាស្រ័យនូវធម៌មិនមែនជាហេតុ មិនមែនជាហេតុនិងមិនមែនជាមិនមានហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

## នហេតុទុកចូឡន្តរទុកៈ

[ ៤៧២ ] ធម៌មិនមែនជាហេតុ មិនមែនជាមិនមានបច្ច័យ អាស្រ័យ

នូវធម៌ មិនមែនជាហេតុ មិនមែនជាមិនមានបច្ច័យ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនជាមិនមែនជាហេតុ មិនមែនជាមិនមានបច្ច័យ អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនជាមិនមានបច្ច័យ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនជាហេតុ មិនមែនជាមិនមានបច្ច័យផង មិនមែនជាមិនមែនជាហេតុ មិនមែនជាមិនមានបច្ច័យផង អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនជាមិនមានបច្ច័យ ទើបកើតឡើងព្រោះហេតុប្បច្ច័យ ។

[ ៤៧៣ ] ធម៌មិនមែនជាមិនមែនជាហេតុ មិនមែនជាមិនមានបច្ច័យ អាស្រ័យនូវធម៌ មិនមែនជាមិនមែនជាហេតុ មិនមែនជាមិនមានបច្ច័យ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនជាហេតុ មិនមែនជាមិនមានបច្ច័យ អាស្រ័យនូវធម៌ មិនមែនជាមិនមែនជាហេតុ មិនមែនជាមិនមានបច្ច័យ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនជាហេតុ មិនមែនជាមិនមានបច្ច័យផង មិនមែនជាមិនមែនជាហេតុ មិនមែនជាមិនមានបច្ច័យផង អាស្រ័យនូវធម៌ មិនមែនជាមិនមែនជាហេតុ មិនមែនជាមិនមានបច្ច័យ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៤៧៤ ] ធម៌មិនមែនជាហេតុ មិនមែនជាមិនមានបច្ច័យ អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនជាមិនមានបច្ច័យផង មិនមែនជាមិនមែនជាហេតុ មិនមែនជាមិនមានបច្ច័យផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនជាមិនមែនជាហេតុ មិនមែនជាមិនមានបច្ច័យ អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនជាមិនមានបច្ច័យផង មិនមែនជាមិនមែនជាហេតុ មិន

មែនជាមិនមានបច្ច័យផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនជាហេតុ មិនមែនជាមិនមានបច្ច័យក្តី មិនមែនជាមិនមែនជាហេតុ មិនមែនជាមិនមានបច្ច័យក្តី អាស្រ័យនូវធម៌មិនមែនជាហេតុ មិនមែនជាមិនមានបច្ច័យផង មិនមែនជាមិនមែនជាហេតុ មិនមែនជាមិនមានបច្ច័យផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៤៧៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ។

[ ៤៧៦ ] អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនជាអសង្ខតៈ... ។ អាស្រ័យនូវធម៌មិនមែនជាហេតុ មិនមែនជាសនិទស្សនៈ... ។ អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនជាសប្បដិឃៈ... អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនជាអប្បដិឃៈ... ។ អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនមានរូប... អាស្រ័យនូវធម៌មិនមែនជាហេតុ មិនមែនជាមិនមានរូប... ។ អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនជាលោកិយ... អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនជាលោកុត្តរៈ... ។ អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនដែលត្រូវដឹងដោយវិញ្ញាណណានីមួយ... អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនជាមិនមែនត្រូវដឹងដោយវិញ្ញាណណានីមួយ... ។

## នហេតុទុកនោអាសវគោច្ឆកទុកៈ

[ ៤៧៧ ] អាស្រ័យនូវធម៌មិនមែនជាហេតុ មិនមែនជាអាសវៈ... អា-ស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនជាមិនមែនអាសវៈ... ។ អាស្រ័យនូវធម៌មិនមែនជាហេតុ មិនមែនប្រព្រឹត្តទៅជាមួយនឹងអាសវៈ... អាស្រ័យនូវធម៌មិនមែនជាហេតុ មិនមែនជាមិនមានអាសវៈ... ។ អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនប្រកបដោយអាសវៈ... អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនប្រាសចាកអាសវៈ... ។ អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនជាអាសវៈ ទាំងមិនមែនជាមិនមានអាសវៈ... អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនជាមិនមានអាសវៈទាំងមិនមែនជាមិនមែនអាសវៈ... ។ អាស្រ័យនូវធម៌មិនមែនជាហេតុ មិនមែនជាអាសវៈ ទាំងមិនមែនប្រាសចាកអាសវៈ .. អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនប្រាសចាកអាសវៈ ទាំងមិនមែនជាមិនមែនអាសវៈ... ។ អាស្រ័យនូវធម៌ មិនមែនជាហេតុ ប្រាសចាកអាសវៈ និងមិនមែនប្រព្រឹត្តទៅជាមួយនឹងអាសវៈ... អាស្រ័យនូវធម៌ មិនមែនជាហេតុ ប្រាសចាកអាសវៈ និងមិនមែនជាមិនមានអាសវៈ... ។

## នហេតុទុកនគោច្ឆកទុកៈ

[ ៤៧៨ ] អាស្រ័យនូវធម៌មិនមែនជាហេតុ មិនមែនជាសញ្ញោជនៈ... អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនជាគន្ថៈ... អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនជាឱឃៈ... អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែន

ជាយោគៈ... អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនជានីវរណៈ... អា-ស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនជាបរាមាសៈ... ។

## នហេតុទុកមហន្តរទុកៈ

[ ៤៧៩ ] អាស្រ័យនូវធម៌មិនមែនជាហេតុ មិនមែនប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍... ។ សេចក្ដីបំប្រួញ ។ អាស្រ័យនូវធម៌មិនមែនជាហេតុ មិនមែនជាចិត្ត... ។ អាស្រ័យនូវធម៌មិនមែនជាហេតុ មិនមែនជាចេតសិក... ។ មិនមែនជាហេតុ មិនមែនប្រកបដោយចិត្ត... ។ មិនមែនជាហេតុ មិនមែនលាយឡំដោយចិត្ត... ។ មិនមែនជាហេតុ មិនមែនតាំងឡើង អំពីចិត្ត... ។ អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនកើតជាមួយនឹងចិត្ត... ។ អា-ស្រ័យនូវធម៌មិនមែនជាហេតុ មិនមែនប្រព្រឹត្តទៅតាមចិត្ត... ។ មិនមែនជាហេតុ មិនមែនលាយឡំ និងតាំងឡើងអំពីចិត្ត... ។ មិនមែនជាហេតុ មិនមែនលាយឡំ តាំងឡើង និងកើតជាមួយនឹងចិត្ត... ។ អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនលាយឡំ តាំងឡើង និងប្រព្រឹត្តទៅតាមចិត្ត... ។ មិនមែនជាហេតុ មិនមែនប្រព្រឹត្តទៅខាងក្នុង... មិនមែនជាហេតុ មិនមែនប្រព្រឹត្តទៅខាងក្រៅ... ។ នូវធម៌មិនមែនជាហេតុ មិនមែនជាឧបាទា... ។ មិនមែនជាហេតុ មិនមែនជាឧបាទិន្ន... មិនមែនជាហេតុ មិនមែនជាអនុបាទិន្ន... ។

## នហេតុទុកទ្វិគោច្ឆកទុកៈ

[ ៤៨០ ] មិនមែនជាហេតុ មិនមែនជាឧបាទាន... មិនមែនជាហេតុ មិនមែនជាកិលេស... ។

## នហេតុទុកបិដ្ឋិទុកៈ

[ ៤៨១ ] មិនមែនជាហេតុ មិនមែនត្រូវលះដោយទស្សនៈ... មិនមែនជាហេតុ មិនមែនជាមិនមែនត្រូវលះដោយទស្សនៈ... ។ មិនមែនជាហេតុ មិនមែនត្រូវលះដោយភាវនា... មិនមែនជាហេតុ មិនមែនជាមិនមែនត្រូវលះដោយភាវនា... ។ អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនមានហេតុដែលត្រូវលះដោយទស្សនៈ... អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនជាមិនមែនមានហេតុដែលត្រូវលះដោយទស្សនៈ... ។ អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនមានហេតុដែលត្រូវលះដោយភាវនា... អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនជាមិនមែនមានហេតុ ដែលត្រូវលះដោយភាវនា... ។ អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ... អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនជាមិនមានវិតក្កៈ... ។ មិនមែនជាហេតុ មិនមែនប្រព្រឹត្តទៅជាមួយនឹងវិចារៈ... មិនមែនជាហេតុ មិនមែនជាមិនមានវិចារៈ... ។ មិនមែនជាហេតុ មិនមែនប្រព្រឹត្តទៅជាមួយនឹងបីតិ... អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនជាមិនមានបីតិ... ។ មិនមែនជាហេតុ មិនមែនប្រកបដោយបីតិ... មិនមែនជាហេតុ មិនមែនជាមិនមែន

ប្រកបដោយបីតិ... ។ មិនមែនជាហេតុ មិនមែនប្រកបដោយសុខ... មិនមែនជាហេតុ មិនមែនជាមិនមែនប្រកបដោយសុខ... ។ មិនមែនជាហេតុ មិនមែនប្រកបដោយឧបេក្ខា... មិនមែនជាហេតុ មិនមែនជាមិនមែនប្រកបដោយឧបេក្ខា... ។ មិនមែនជាហេតុ មិនមែនជាកាមាវចរៈ... មិនមែនជាហេតុ មិនមែនជាមិនមែនកាមាវចរៈ... ។ មិនមែនជាហេតុ មិនមែនជារូបាវចរៈ... មិនមែនជាហេតុ មិនមែនជាមិនមែនរូបាវចរៈ... ។ មិនមែនជាហេតុ មិនមែនជាអរូបាវចរៈ... មិនមែនជាហេតុ មិនមែនជាមិនមែនអរូបាវចរៈ... ។ មិនមែនជាហេតុ មិនមែនជាបរិយាបន្នៈ... មិនមែនជាហេតុ មិនមែនជាអបរិយាបន្នៈ... ។ មិនមែនជាហេតុ មិនមែនជានិយ្យានិកៈ... មិនមែនជាហេតុ មិនមែនជាអនិយ្យានិកៈ... ។ មិនមែនជាហេតុ មិនមែនជានិយតៈ... មិនមែនជាហេតុ មិនមែនជាអនិយតៈ... ។ មិនមែនជាហេតុ មិនមែនប្រព្រឹត្តទៅជាមួយនឹងឧត្តរៈ... មិនមែនជាហេតុ មិនមែនជាមិនមានឧត្តរៈ... ។

[ ៤៨២ ] ធម៌មិនមែនជាហេតុ មិនមែនជាសរណៈ ( មានកិលេស ) អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៩ ។ ធម៌មិនមែនជាហេតុ មិនមែនជាអរណៈ ( មិនមានកិលេស ) អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនជាមិនមែនជាហេតុ មិនមែនជាអរណៈ អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនជាហេតុ មិនមែនជាអរណៈក្តី មិន

មែនជាមិនមែនជាហេតុ មិនមែនជាអរណៈក្តី អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនជាមិនមានកិលេស ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៤៨៣ ] ធម៌មិនមែនជាមិនមែនជាហេតុ មិនមែនជាអរណៈ អាស្រ័យនូវធម៌ មិនមែនជាមិនមែនជាហេតុ មិនមែនជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនជាហេតុ មិនមែនជាអរណៈ អាស្រ័យនូវធម៌មិនមែនជាមិនមែនជាហេតុ មិនមែនជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនជាហេតុ មិនមែនជាអរណៈក្តី មិនមែនជាមិនមែនជាហេតុ មិនមែនជាអរណៈក្តី អាស្រ័យនូវធម៌ មិនមែនជាមិនមែនជាហេតុ មិនមែនជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៤៨៤ ] ធម៌មិនមែនជាហេតុ មិនមែនជាអរណៈ អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនជាអរណៈផង មិនមែនជាមិនមែនជាហេតុ មិនមែនជាអរណៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនជាមិនមែនជាហេតុ មិនមែនជាអរណៈ អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនជាអរណៈផង មិនមែនជាមិនមែនជាហេតុ មិនមែនជាអរណៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនជាហេតុ មិនមែនជាអរណៈក្តី មិនមែនជាមិនមែនជាហេតុ មិនមែនជាអរណៈក្តី អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនជាអរណៈផង មិនមែនជាមិនមែនជាហេតុ មិនមែនជាអរណៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៤៨៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែ

មានវារៈ ៩ ។

# ឆសហេតុកទុកនហេតុទុកៈ

[ ៤៨៦ ] ធម៌មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ មិនមែនជាហេតុ អាស្រ័យនូវធម៌ មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនជាមិនមានហេតុ មិនមែនជាហេតុ អាស្រ័យនូវធម៌ មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ មិនមែនជាហេតុក្តី មិនមែនជាមិនមានហេតុ មិនមែនជាហេតុក្តី អាស្រ័យនូវធម៌ មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៤៨៧ ] ធម៌មិនមែនជាមិនមានហេតុ មិនមែនជាហេតុ អាស្រ័យនូវធម៌ មិនមែនជាមិនមានហេតុ មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ មិនមែនជាហេតុ អាស្រ័យនូវធម៌មិនមែនជាមិនមានហេតុ មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ មិនមែនជាហេតុក្តី មិនមែនជាមិនមានហេតុ មិនមែនជាហេតុក្តី អាស្រ័យនូវធម៌ មិនមែនជាមិនមានហេតុ មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៤៨៨ ] ធម៌មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ មិនមែនជាហេតុ អាស្រ័យនូវធម៌មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ មិនមែនជាហេតុផង មិនមែនជាមិនមានហេតុ មិនមែនជាហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាមិនមានហេតុ មិនមែនជាហេតុ អាស្រ័យនូវធម៌ មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ មិនមែនជាហេតុផង មិនមែនជាមិនមានហេតុ មិនមែនជាហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ មិនមែនជាហេតុក្តី មិនមែនជាមិនមានហេតុ មិនមែនជាហេតុក្តី អាស្រ័យនូវធម៌ មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ មិនមែនជាហេតុផង មិនមែនជាមិនមានហេតុ មិនមែនជាហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៤៨៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

[ ៤៩០ ] ធម៌មិនមែនជាមិនមានហេតុ មិនមែនជាមិនមែនជាហេតុ អាស្រ័យនូវធម៌ មិនមែនជាមិនមានហេតុ មិនមែនជាមិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៤៩១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ១ ។

## នហេតុសម្បយុត្តទុកនហេតុទុកៈ

[ ៤៩២ ] អាស្រ័យនូវធម៌ មិនមែនប្រកបដោយហេតុ មិនមែនជាហេតុ... អាស្រ័យនូវធម៌ មិនមែនប្រាសចាកហេតុ មិនមែនជាហេតុ... ។

## នហេតុសហេតុកទុកនហេតុទុកៈ

[ ៤៩៣ ] អាស្រ័យនូវធម៌ មិនមែនជាហេតុ ទាំងមិនមែនជាមិនមានហេតុ មិនមែនជាហេតុ... អាស្រ័យនូវធម៌ មិនមែនជាមិនមានហេតុ ទាំងមិនមែនជាមិនមែនជាហេតុ មិនមែនជាមិនមែនជាហេតុ... ។

## នហេតុហេតុសម្បយុត្តទុកនហេតុទុកៈ

[ ៤៩៤ ] អាស្រ័យនូវធម៌ មិនមែនជាហេតុ ទាំងមិនមែនប្រាសចាកហេតុ មិនមែនជាហេតុ... អាស្រ័យនូវធម៌ មិនមែនប្រាសចាកហេតុ ទាំងមិនមែនជាមិនមែនជាហេតុ មិនមែនជាមិនមែនជាហេតុ... ។

## នហេតុនសហេតុកទុកនហេតុទុកៈ

[ ៤៩៥ ] អាស្រ័យនូវធម៌ មិនមែនជាហេតុ និងមិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ មិនមែនជាហេតុ... អាស្រ័យនូវធម៌ មិនមែនជាហេតុនិងមិនមែនជាមិនមានហេតុ មិនមែនជាហេតុ... ។

## ចូឡន្តរទុកនហេតុទុកៈ

[ ៤៩៦ ] អាស្រ័យនូវធម៌មិនមែនជាមិនមានបច្ច័យ មិនមែនជាហេតុ... ។ អាស្រ័យនូវធម៌ មិនមែនជាអសង្ខតៈ មិនមែនជាហេតុ... ។ អាស្រ័យនូវធម៌ មិនមែនជាសនិទស្សនៈ មិនមែនជាហេតុ... ។ អាស្រ័យនូវធម៌ មិនមែនជាសប្បដិឃៈ មិនមែនជាហេតុ... ។ អាស្រ័យនូវធម៌ មិនមែនជាអប្បដិឃៈ មិនមែនជាហេតុ... ។ អាស្រ័យនូវធម៌ មិនមែនមានរូប មិនមែនជាហេតុ... អាស្រ័យនូវធម៌មិនមែនជាមិនមានរូប មិនមែនជាហេតុ... អាស្រ័យនូវធម៌មិនមែនជាលោកិយ មិនមែនជាហេតុ... ។ អាស្រ័យនូវធម៌ មិនមែនជាលោកុត្តរៈ មិនមែនជាហេតុ... ។ អាស្រ័យនូវធម៌ មិនមែនត្រូវដឹងដោយវិញ្ញាណណានីមួយ មិនមែនជាហេតុ... អាស្រ័យនូវធម៌ មិនមែនជាមិនមែនត្រូវដឹងដោយវិញ្ញាណណានីមួយ មិនមែនជាហេតុ... ។

## នោអាសវគោច្ឆកទុកនហេតុទុកៈ

[ ៤៩៧ ] អាស្រ័យនូវធម៌ មិនមែនជាអាសវៈ មិនមែនជាហេតុ... អាស្រ័យនូវធម៌ មិនមែនជាមិនមែនជាអាសវៈ មិនមែនជាហេតុ... ។ អាស្រ័យនូវធម៌ មិនមែនប្រព្រឹត្តទៅជាមួយនឹងអាសវៈ មិនមែនជាហេតុ... អាស្រ័យនូវធម៌មិនមែនជាមិនមានអាសវៈ មិនមែនជាហេតុ... ។ អាស្រ័យនូវធម៌ មិនមែនប្រកបដោយអាសវៈ មិនមែនជាហេតុ... អាស្រ័យនូវធម៌ មិនមែនប្រាសចាកអាសវៈ មិនមែនជាហេតុ... ។ អាស្រ័យនូវធម៌ មិនមែន

ជាអាសវៈ ទាំងមិនមែនជាមិនមានអាសវៈ មិនមែនជាហេតុ... អាស្រ័យនូវធម៌មិនមែនជាមិនមានអាសវៈទាំងមិនមែនជាមិនមែនជាអាសវៈ មិនមែនជាហេតុ... ។ អាស្រ័យនូវធម៌ មិនមែនជាអាសវៈ ទាំងមិនមែនប្រាសចាកអាសវៈ មិនមែនជាហេតុ... អាស្រ័យនូវធម៌មិនមែនប្រាសចាកអាសវៈ ទាំងមិនមែនជាមិនមែនជាអាសវៈ មិនមែនជាហេតុ... ។ អាស្រ័យនូវធម៌ ប្រាសចាកអាសវៈ និងមិនមែនប្រព្រឹត្តទៅជាមួយនឹងអាសវៈ មិនមែនជាហេតុ... អាស្រ័យនូវធម៌ ប្រាសចាកអាសវៈ និងមិនមែនជាមិនមានអាសវៈ មិនមែនជាហេតុ... ។

## ឆគោច្ឆកទុកនហេតុទុកៈ

[ ៤៩៨ ] អាស្រ័យនូវធម៌មិនមែនជាសញ្ញោជនៈ មិនមែនជាហេតុ... អាស្រ័យនូវធម៌ មិនមែនជាគន្ថៈ មិនមែនជាហេតុ... អាស្រ័យនូវធម៌ មិនមែនជាឱឃៈ មិនមែនជាហេតុ... អាស្រ័យនូវធម៌ មិនមែនជាយោគៈ មិនមែនជាហេតុ... អាស្រ័យនូវធម៌មិនមែនជានីវរណៈ មិនមែនជាហេតុ... អាស្រ័យនូវធម៌ មិនមែនជាបរាមាសៈ មិនមែនជាហេតុ... ។

## មហន្តរទុកនហេតុទុកៈ

[ ៤៩៩ ] អាស្រ័យនូវធម៌ មិនមែនប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍

មិនមែនជាហេតុ... ។ សេចក្តីបំប្រួញ ។ អាស្រ័យនូវធម៌ មិនមែនជាចិត្ត មិនមែនជាហេតុ... ។ អាស្រ័យនូវធម៌ មិនមែនជាចេតសិក មិនមែនជាហេតុ... ។ អាស្រ័យនូវធម៌ មិនមែនប្រកបដោយចិត្ត មិនមែនជាហេតុ... ។ អាស្រ័យនូវធម៌មិនមែនលាយឡំដោយចិត្ត មិនមែនជាហេតុ... ។ អាស្រ័យនូវធម៌មិនមែនតាំងឡើងអំពីចិត្ត មិនមែនជាហេតុ... ។ អាស្រ័យនូវធម៌មិនមែនកើតជាមួយនឹងចិត្ត មិនមែនជាហេតុ... ។ អាស្រ័យនូវធម៌ មិនមែនប្រព្រឹត្តទៅតាមចិត្ត មិនមែនជាហេតុ... ។ អាស្រ័យនូវធម៌ មិនមែនលាយឡំ និងតាំងឡើងអំពីចិត្ត មិនមែនជាហេតុ... ។ អាស្រ័យនូវធម៌ មិនមែនលាយឡំ តាំងឡើងនិងកើតជាមួយនឹងចិត្ត មិនមែនជាហេតុ... ។ អាស្រ័យនូវធម៌មិនមែនលាយឡំ តាំងឡើងនិងប្រព្រឹត្តទៅតាមចិត្ត មិនមែនជាហេតុ... ។ អាស្រ័យនូវធម៌ មិនមែនប្រព្រឹត្តទៅខាងក្នុង មិនមែនជាហេតុ... អាស្រ័យនូវធម៌ មិនមែនប្រព្រឹត្តទៅខាងក្រៅ មិនមែនជាហេតុ... ។ អាស្រ័យនូវធម៌ មិនមែនជាឧបាទា មិនមែនជាហេតុ... ។ អាស្រ័យនូវធម៌ មិនមែនជាឧបាទិន្ន មិនមែនជាហេតុ... អាស្រ័យនូវធម៌ មិនមែនជាអនុបាទិន្ន មិនមែនជាហេតុ... ។

## ទុកគោច្ឆកទុកនហេតុទុកៈ

[ ៥០០ ] អាស្រ័យនូវធម៌ មិនមែនជាឧបាទាន មិនមែនជាហេតុ... ។

អាស្រ័យនូវធម៌ មិនមែនជាកិលេស មិនមែនជាហេតុ... អាស្រ័យនូវធម៌មិនមែនជាមិនមែនជាកិលេស មិនមែនជាហេតុ... ។

## បិដ្ឋិទុកនហេតុទុកៈ

[ ៥០១ ] អាស្រ័យនូវធម៌ មិនមែនត្រូវលះដោយទស្សនៈ មិនមែនជាហេតុ... អាស្រ័យនូវធម៌ មិនមែនជាមិនមែនត្រូវលះដោយទស្សនៈ មិនមែនជាហេតុ... ។ អាស្រ័យនូវធម៌ មិនមែនត្រូវលះដោយភាវនា មិនមែនជាហេតុ... អាស្រ័យនូវធម៌ មិនមែនជាមិនមែនត្រូវលះដោយភាវនា មិនមែនជាហេតុ... ។ អាស្រ័យនូវធម៌ មិនមែនមានហេតុដែលត្រូវលះដោយទស្សនៈ មិនមែនជាហេតុ... អាស្រ័យនូវធម៌ មិនមែនជាមិនមែនមានហេតុដែលត្រូវលះដោយទស្សនៈ មិនមែនជាហេតុ... ។ អាស្រ័យនូវធម៌ មិនមែនមានហេតុដែលត្រូវលះដោយភាវនា មិនមែនជាហេតុ... អាស្រ័យនូវធម៌ មិនមែនជាមិនមែនមានហេតុដែលត្រូវលះដោយភាវនា មិនមែនជាហេតុ... ។ អាស្រ័យនូវធម៌ មិនមែនប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ មិនមែនជាហេតុ... អាស្រ័យនូវធម៌ មិនមែនជាមិនមានវិតក្កៈ មិនមែនជាហេតុ... ។ អាស្រ័យនូវធម៌ មិនមែនប្រព្រឹត្តទៅជាមួយនឹងវិចារៈ មិនមែនជាហេតុ... អាស្រ័យនូវធម៌ មិនមែនជាមិនមានវិចារៈ មិនមែនជាហេតុ... ។ អាស្រ័យនូវធម៌ មិនមែនប្រព្រឹត្តទៅជាមួយនឹងបីតិ មិនមែនជាហេតុ... អាស្រ័យនូវធម៌ មិន

មែនជាមិនមានបីតិ មិនមែនជាហេតុ... ។ អាស្រ័យនូវធម៌ មិនមែនប្រកប ដោយបីតិ មិនមែនជាហេតុ... អាស្រ័យនូវធម៌ មិនមែនជាមិនមែនប្រកប ដោយបីតិ មិនមែនជាហេតុ... ។ អាស្រ័យនូវធម៌មិនមែនប្រកបដោយសុខ មិនមែនជាហេតុ... អាស្រ័យនូវធម៌ មិនមែនជាមិនមែនប្រកបដោយសុខ មិនមែនជាហេតុ... ។ អាស្រ័យនូវធម៌ មិនមែនប្រកបដោយឧបេក្ខា មិន មែនជាហេតុ... អាស្រ័យនូវធម៌ មិនមែនជាមិនមែនប្រកបដោយឧបេក្ខា មិន មែនជាហេតុ... ។ អាស្រ័យនូវធម៌ មិនមែនជាកាមាវចរៈ មិនមែនជា ហេតុ... អាស្រ័យនូវធម៌ មិនមែនជាមិនមែនជាកាមាវចរៈ មិនមែនជា ហេតុ... ។ អាស្រ័យនូវធម៌ មិនមែនជារូបាវចរៈ មិនមែនជាហេតុ... អា-ស្រ័យនូវធម៌មិនមែនជាមិនមែនជារូបាវចរៈ មិនមែនជាហេតុ... ។ អាស្រ័យ នូវធម៌ មិនមែនជាអរូបាវចរៈ មិនមែនជាហេតុ... អាស្រ័យនូវធម៌ មិនមែន ជាមិនមែនជាអរូបាវចរៈ មិនមែនជាហេតុ... ។ អាស្រ័យនូវធម៌ មិនមែនជា បរិយាបន្នៈ មិនមែនជាហេតុ... អាស្រ័យនូវធម៌ មិនមែនជាអបរិយាបន្នៈ មិនមែនជាហេតុ... ។ អាស្រ័យនូវធម៌ មិនមែនជានិយ្យានិកៈ មិនមែនជា ហេតុ... អាស្រ័យនូវធម៌ មិនមែនជានិយ្យានិកៈ មិនមែនជាហេតុ... ។ អា-ស្រ័យនូវធម៌ មិនមែនជានិយតៈ មិនមែនជាហេតុ... អាស្រ័យនូវធម៌ មិន មែនជាអនិយតៈ មិនមែនជាហេតុ... ។ អាស្រ័យនូវធម៌មិនមែនជាសឧត្តរៈ មិនមែនជាហេតុ... អាស្រ័យនូវធម៌មិនមែនជាអនុត្តរៈ មិនមែនជាហេតុ... ។

[ ៥០២ ] ធម៌មិនមែនជាសរណៈ ( មិនមែនប្រព្រឹត្តទៅជាមួយនឹង

កិលេស ) មិនមែនជាហេតុ អាស្រ័យនូវធម៌មិនមែនជាសរណៈ មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌មិនមែនជាអរណៈ ( មិនមែនជាមិនមានកិលេស ) មិនមែនជាហេតុ អាស្រ័យនូវធម៌ មិនមែនជាអរណៈ មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនជាសរណៈ មិនមែនជាហេតុ អាស្រ័យនូវធម៌ មិនមែនជាអរណៈ មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនជាសរណៈមិនមែនជាហេតុក្តី មិនមែនជាអរណៈ មិនមែនជាហេតុក្តី អាស្រ័យនូវធម៌ មិនមែនជាអរណៈ មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌មិនមែនជាសរណៈ មិនមែនជាហេតុ អាស្រ័យនូវធម៌មិនមែនជាសរណៈ មិនមែនជាហេតុផង មិនមែនជាអរណៈ មិនមែនជាហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៥០៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

[ ៥០៤ ] ធម៌មិនមែនជាសរណៈ មិនមែនជាមិនមែនជាហេតុ អាស្រ័យនូវធម៌មិនមែនជាសរណៈ មិនមែនជាមិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌មិនមែនជាអរណៈ មិនមែនជាមិនមែនជាហេតុ អាស្រ័យនូវធម៌ មិនមែនជាអរណៈ មិនមែនជាមិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៥០៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ

២ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

## ឆសរណាទុកកងសហេតុកទុកៈ

[ ៥០៦ ] អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ... អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាមិនមានហេតុ... ។

## ឆសរណាទុកកងហេតុសម្បយុត្តទុកៈ

[ ៥០៧ ] អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនប្រកបដោយហេតុ... អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនប្រាសចាកហេតុ... ។

## ឆសរណាទុកកងហេតុសហេតុកទុកៈ

[ ៥០៨ ] អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាហេតុទាំងមិនមែនជាមិនមានហេតុ... អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាមិនមានហេតុទាំងមិនមែនជាមិនមែនជាហេតុ... ។

## នសារណទុកនហេតុហេតុសម្បយុត្តទុកៈ

[ ៥០៩ ] អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាហេតុទាំង មិនមែនប្រាសចាកហេតុ... អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែន ប្រាសចាកហេតុទាំងមិនមែនជាមិនមែនជាហេតុ... ។

## នសារណទុកនហេតុនសហេតុកទុកៈ

[ ៥១០ ] អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាហេតុនិង មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ... អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាហេតុនិងមិនមែនជាមិនមានហេតុ... ។

## សារណទុកចូឡន្តរទុកៈ

[ ៥១១ ] អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាមិនមាន បច្ច័យ... ។ អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាអសង្ខតៈ... ។ អាស្រ័យនូវធម៌មិនមែនជាសរណៈ មិនមែនជាសនិទស្សនៈ... ។ អាស្រ័យ នូវធម៌មិនមែនជាសរណៈ មិនមែនជាសប្បដិឃៈ... អាស្រ័យនូវធម៌ មិន មែនជាសរណៈ មិនមែនជាអប្បដិឃៈ... ។ អាស្រ័យនូវធម៌ មិនមែនជា សរណៈ មិនមែនមានរូប... អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែន ជាមិនមានរូប... ។ អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាលោ-

កិយ... អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាលោកុត្តរៈ... ។ អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនត្រូវដឹងដោយវិញ្ញាណណានីមួយ... អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាមិនមែនត្រូវដឹងដោយវិញ្ញាណណានីមួយ... ។

## ធសរណទុកនោអាសវគោច្ឆកទុកៈ

[ ៥១២ ] អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាអាសវៈ... អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាមិនមែនជាអាសវៈ... ។ អាស្រ័យនូវធម៌មិនមែនជាសរណៈ មិនមែនប្រព្រឹត្តទៅជាមួយនឹងអាសវៈ... អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាមិនមានអាសវៈ... ។ អាស្រ័យនូវធម៌មិនមែនជាសរណៈ មិនមែនប្រកបដោយអាសវៈ... អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនប្រាសចាកអាសវៈ... ។ អាស្រ័យនូវធម៌មិនមែនជាសរណៈ មិនមែនជាអាសវៈទាំងមិនមែនជាមិនមានអាសវៈ... អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាមិនមានអាសវៈ ទាំងមិនមែនជាមិនមែនជាអាសវៈ... ។ អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាអាសវៈ ទាំងមិនមែនប្រាសចាកអាសវៈ... អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនប្រាសចាកអាសវៈទាំងមិនមែនជាមិនមានអាសវៈ ... ។ អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនប្រាសចាកអាសវៈនិងមិនមែន

ប្រព្រឹត្តទៅជាមួយនឹងអាសវៈ... អាស្រ័យនូវធម៌មិនមែនជាសរណៈ ប្រាស ចាកអាសវៈ និងមិនមែនជាមិនមានអាសវៈ... ។

## នសរណទុកគោច្ឆកទុកៈ

[ ៥១៣ ] អាស្រ័យនូវធម៌មិនមែនជាសរណៈ មិនមែនជាសញ្ញោជនៈ... អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាគន្ថៈ... អាស្រ័យនូវធម៌មិន មែនជាសរណៈ មិនមែនជាឱឃៈ... អាស្រ័យនូវធម៌ មិនមែនជាសរណៈមិន មែនជាយោគៈ... អាស្រ័យនូវធម៌មិនមែនជាសរណៈ មិនមែនជានីវរណៈ... អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាបរាមាសៈ... ។

## នសរណទុកមហន្តរទុកៈ

[ ៥១៤ ] អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនប្រព្រឹត្តទៅជា មួយនឹងអារម្មណ៍... ។ សេចក្តីបំប្រួញ ។ អាស្រ័យនូវធម៌ មិនមែនជា សរណៈ មិនមែនជាចិត្ត... ។ អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិន មែនជាចេតសិក... ។ អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនប្រកប ដោយចិត្ត... ។ អាស្រ័យនូវធម៌មិនមែនជាសរណៈ មិនមែនលាយឡំដោយ ចិត្ត... ។ អាស្រ័យនូវធម៌មិនមែនជាសរណៈ មិនមែនតាំងឡើងអំពីចិត្ត... ។ អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនកើតជាមួយនឹងចិត្ត... ។ អា-

ស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនប្រព្រឹត្តទៅតាមចិត្ត... ។ អាស្រ័យនូវធម៌មិនមែនជាសរណៈ មិនមែនលាយឡំនិងតាំងឡើងអំពីចិត្ត... ។ អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនលាយឡំ តាំងឡើងនិងកើតជាមួយនឹងចិត្ត... ។ អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនលាយឡំ តាំងឡើង និងប្រព្រឹត្តទៅតាមចិត្ត... ។ អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនប្រព្រឹត្តទៅខាងក្នុង... អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនប្រព្រឹត្តទៅខាងក្រៅ... ។ អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាឧបាទា... ។ អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាឧបាទិន្ន... អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាអនុបាទិន្ន... ។

## នសរណទុកឧបាទានគោច្ឆកទុកៈ

[ ៥១៥ ] អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាឧបាទាន... អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាកិលេស... ។

## នសរណទុកបិដ្ឋិទុកៈ

[ ៥១៦ ] អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនត្រូវលះដោយទស្សនៈ... អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាមិនមែនត្រូវលះដោយទស្សនៈ... ។ អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនត្រូវលះ

ដោយភាវនា... អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាមិនមែនត្រូវលះដោយភាវនា... ។ អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនមានហេតុដែលត្រូវលះដោយទស្សនៈ... អាស្រ័យនូវធម៌មិនមែនជាសរណៈ មិនមែនជាមិនមែនមានហេតុដែលត្រូវលះដោយទស្សនៈ... ។ អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនមានហេតុ ដែលត្រូវលះដោយភាវនា... អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាមិនមែនមានហេតុដែលត្រូវលះដោយភាវនា... ។ អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ... អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាមិនមានវិតក្កៈ... ។ អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនប្រព្រឹត្តទៅជាមួយនឹងវិចារៈ... អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាមិនមានវិចារៈ... ។ អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនប្រព្រឹត្តទៅជាមួយនឹងបីតិ... អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាមិនមានបីតិ... ។ អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនប្រកបដោយបីតិ... អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាមិនមែនប្រកបដោយបីតិ... ។ អាស្រ័យនូវធម៌មិនមែនជាសរណៈ មិនមែនប្រកបដោយសុខ... អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាមិនមែនប្រកបដោយសុខ... ។ អាស្រ័យនូវធម៌ មិនមែនជាសរណៈមិនមែនប្រកបដោយឧបេក្ខា... អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាមិនមែនប្រកបដោយឧបេក្ខា... ។ អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាកាមាវចរៈ... អាស្រ័យនូវ

ធម៌ មិនមែនជាសរណៈ មិនមែនជាមិនមែនជាកាមាវចរៈ... ។ អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជារូបាវចរៈ... អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាមិនមែនជារូបាវចរៈ... ។ អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាអរូបាវចរៈ... អាស្រ័យនូវធម៌មិនមែនជាសរណៈ មិនមែនជាមិនមែនជាអរូបាវចរៈ... ។ អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាបរិយាបន្នៈ... អាស្រ័យនូវធម៌មិនមែនជាសរណៈ មិនមែនជាអបរិ-យាបន្នៈ... ។ អាស្រ័យនូវធម៌មិនមែនជាសរណៈ មិនមែនជានិយ្យានិកៈ... អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាអនិយ្យានិកៈ... ។ អា-ស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជានិយតៈ... អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាអនិយតៈ... ។

[ ៥១៧ ] ធម៌មិនមែនជាសរណៈ មិនមែនជាសឧត្តរៈ អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាសឧត្តរៈ ទើបកើតឡើង ព្រោះហេ-តុប្បច្ច័យ ។

[ ៥១៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ សេចក្តីពិស្តារមានគ្រប់បច្ច័យទាំងអស់ ។

[ ៥១៩ ] ធម៌មិនមែនជាសរណៈ មិនមែនជាអនុត្តរៈ អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាអនុត្តរៈ ទើបកើតឡើង ព្រោះហេ-តុប្បច្ច័យ មានវារៈ ១ ។ ធម៌មិនមែនជាអរណៈ មិនមែនជាអនុត្តរៈ អា-ស្រ័យនូវធម៌ មិនមែនជាអរណៈ មិនមែនជាអនុត្តរៈ ទើបកើតឡើង ព្រោះ

ហេតុប្បច្ច័យ ធម៌មិនមែនជាសរណៈ មិនមែនជាអនុត្តរៈ អាស្រ័យនូវធម៌ មិនមែនជាអរណៈ មិនមែនជាអនុត្តរៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនជាសរណៈ មិនមែនជាអនុត្តរៈក្តី មិនមែនជាអរណៈ មិនមែនជាអនុត្តរៈក្តី អាស្រ័យនូវធម៌មិនមែនជាអរណៈ មិនមែនជាអនុត្តរៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌មិនមែនជាសរណៈមិនមែនជាអនុត្តរៈ អាស្រ័យនូវធម៌ មិនមែនជាសរណៈ មិនមែនជាអនុត្តរៈផង មិនមែនជាអរណៈ មិនមែនជាអនុត្តរៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៥២០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ សេចក្តីពិស្តារមានគ្រប់បច្ច័យទាំងអស់ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី
សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី បញ្ហាវារៈក្តី
បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

**ចប់ បច្ចនីយទុកទុកប្បដ្ឋាន ។**

# អដ្ឋកថា

## បច្ចនីយប្បដ្ឋាន

[ ១-៥២០ ] ឥឡូវនេះ ដើម្បីនឹងសម្ដែងបច្ចនីយប្បដ្ឋាន ដែលមានឈ្មោះបានហើយ ព្រោះជាធម៌ផ្សាយដោយអំណាចជាបដិបក្ខ ចំពោះបទទាំងឡាយ មានកុសលជាដើម ទើបព្រះមានព្រះភាគផ្ដើមពាក្យថា **ន កុសលំ ធម្មំ បដិច្ច ន កុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ ព្រះមានព្រះភាគ ទ្រង់ហាមភាពដែលកុសលជាបច្ច័យដោយពាក្យថា **ន កុសលំ ធម្មំ បដិច្ច** ទ្រង់ហាមការកើតឡើងនៃកុសលដោយពាក្យថា **ន កុសលោ ធម្មោ ឧប្បជ្ជតិ** ព្រោះហេតុនោះ អ្នកសិក្សាគប្បីជ្រាបបញ្ហានិងវិសជ្ជនាក្នុងអធិការនេះ ដោយន័យជាដើម យ៉ាងនេះថា ខន្ធ ៣ ដែលជាអកុសលាព្យាកតៈនិងរូបដែលមានចិត្តជាសមុដ្ឋាន អាស្រ័យខន្ធ ១ ដែលជាអកុសលាព្យាកតៈកើតឡើង ។

វិធីរាប់ដែលបានក្នុងបច្ច័យនោះៗ ព្រះមានព្រះភាគត្រាស់ទុកហើយ ក្នុងបាលីនោះឯង សូម្បីវារៈទាំងឡាយ ដែលមានវិសជ្ជនាដូចគ្នា ក៏ទ្រង់សម្ដែងទុកក្នុងបាលីនោះឯង ព្រោះហេតុនោះ ក្នុងអធិការនេះ អ្នកសិក្សាគប្បីកំណត់បាលី ហើយជ្រាបបដ្ឋានន័យទាំងអស់ តាមគន្លងរបស់ន័យ ដែលខ្ញុំពោលហើយខាងដើម ។ ក្នុងអធិការនេះយ៉ាងណា ក្នុងទុកប្បដ្ឋាន ទុកត្តិកប្បដ្ឋាន តិកទុកប្បដ្ឋាន តិកត្តិកប្បដ្ឋាននិងទុកទុកប្បដ្ឋាន ក៏មានន័យដូច្នេះឯង ។

ន័យ ៦ ក្នុងធម្មប្បច្ចនីយប្បដ្ឋាន ដែលលោកសម្ដែងទុក ដោយគាថា

ដែលលោកពោលទុកក្នុងអដ្ឋកថាថា

ន័យ ៦ ក្នុងបច្ចនីយប្បដ្ឋាន គឺតិកប្បដ្ឋានដ៏ប្រសើរ ទុកប្បដ្ឋានដ៏ឧត្តម ទុកត្តិកប្បដ្ឋាន តិកទុកប្បដ្ឋាន តិកត្តិកប្បដ្ឋាននិងទុកទុកប្បដ្ឋានដ៏ជ្រាលជ្រៅក្រៃលែង ដូច្នេះ ។ ឈ្មោះថា ខ្ញុំសម្តែងហើយដោយពាក្យមានប្រមាណប៉ុណ្ណេះ ។ ក្នុងអធិការនេះ អ្នកសិក្សា គប្បីជ្រាបចំពោះបច្ចនីយប្បដ្ឋានប៉ុណ្ណោះ ប្រដាប់ដោយន័យ ២៤ ដោយបរិយាយ ១ គឺក្នុងបដ្ឋានទីមួយៗ ពោលដោយអំណាចនៃបច្ច័យទីមួយៗ មាន ៤ ន័យ មានអនុលោមន័យជាដើម ។

## អដ្ឋកថា បច្ចនីយប្បដ្ឋាន ចប់

# អភិធម្មបិដក

## បដ្ឋាន សោឡសមភាគ

## អនុលោមប្បច្ចនីយប្បដ្ឋាន

*សូមនមស្ការ ចំពោះព្រះមានភាគអរហន្តសម្មាសម្ពុទ្ធអង្គនោះ ។*

## អនុលោមប្បច្ចនីយត្តិកប្បដ្ឋាន

### កុសលត្តិកៈ ឆកុសលត្តិកៈ

*[ ១ ] ធម៌មិនមែនជាកុសល អាស្រ័យនូវធម៌ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធជាកុសល ។ ធម៌មិនមែនជាអកុសល អាស្រ័យនូវធម៌ ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវខន្ធ ១ ជាកុសល ។ ធម៌មិនមែនជាអព្យាកតៈ អាស្រ័យនូវធម៌ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជាកុសល ។ ធម៌មិនមែនជាអកុសលក្តី មិនមែនជាអព្យាកតៈក្តី អាស្រ័យនូវធម៌ ជាកុសល ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជាកុសល ។ ធម៌មិនមែនជាកុសលក្តី មិនមែនជាអកុសលក្តី អាស្រ័យនូវធម៌ ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធ ជាកុសល ។ វារៈ ៥ ។*

*[ ២ ] ធម៌មិនមែនជាអកុសល អាស្រ័យនូវធម៌ ជាអកុសល ទើប*

កើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធ ជាអកុសល ។ ធម៌មិនមែនជាកុសល អាស្រ័យនូវធម៌ជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវខន្ធ ១ ជាអកុសល ។ ធម៌មិនមែនជាអព្យាកតៈ អាស្រ័យនូវធម៌ ជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនជាកុសលក្តី មិនមែនជាអព្យាកតៈក្តី អាស្រ័យនូវធម៌ ជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនជាកុសលក្តី មិនមែនជាអកុសលក្តី អាស្រ័យនូវធម៌ជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ វារៈ ៥ ។

[ ៣ ] ធម៌មិនមែនជាកុសល អាស្រ័យនូវធម៌ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ផង ចិត្តសមុដ្ឋានរូបផង ជាបដិសន្ធិ អាស្រ័យនូវខន្ធ ១ ជាវិបាកាព្យាកតៈនិងជាកិរិយាព្យាកតៈ មហាភូត ៣ អាស្រ័យនូវមហាភូត ១ មហាភូត ២ អាស្រ័យនូវមហាភូត ២ ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកមហាភូត ។ ធម៌មិនមែនជាអកុសល អាស្រ័យនូវធម៌ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺវិបាកាព្យាកតបដិសន្ធិនិងមហាភូត ។ ធម៌មិនមែនជាកុសលក្តី មិនមែនជាអកុសលក្តី អាស្រ័យនូវធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺវិបាកាព្យាកតៈនិងកិរិយាព្យាកតៈ ។ សេចក្តីបំប្រួញ ។ វារៈ ៣ ។

[ ៤ ] ធម៌មិនមែនជាកុសល អាស្រ័យនូវធម៌ ជាកុសលផង ជាអព្យាកតៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អា-

ស្រ័យនូវពួកខន្ធ ជាកុសលផង នូវពួកមហាភូតផង ។ ធម៌មិនមែនជាអកុ-សល អាស្រ័យនូវធម៌ ជាកុសលផង ជាអព្យាកតៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនជាកុសលក្តី មិនមែនជាអកុសលក្តី អាស្រ័យនូវធម៌ជាកុសលផង ជាអព្យាកតៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៥ ] ធម៌មិនមែនជាកុសល អាស្រ័យនូវធម៌ ជាអកុសលផង ជាអព្យាកតៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនជាអកុសល អាស្រ័យនូវធម៌ ជាអកុសលផង ជាអព្យាកតៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនជាកុសលក្តី មិនមែនជាអកុសលក្តី អាស្រ័យនូវធម៌ ជាអកុសលផង ជាអព្យាកតៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូបតែម្យ៉ាង ប្រព្រឹត្តទៅក្នុងតិកៈនេះ ។

បញ្ហា ១៩ បណ្ឌិត គប្បីធ្វើផងចុះ ។

[ ៦ ] ធម៌មិនមែនជាអកុសល អាស្រ័យនូវធម៌ ជាកុសល ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ធម៌មិនមែនជាអព្យាកតៈ អាស្រ័យនូវធម៌ជាកុសល ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ធម៌មិនមែនជាអកុ-សលក្តី មិនមែនជាអព្យាកតៈក្តី អាស្រ័យនូវធម៌ជាកុសល ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ មានវារៈ ៣ ។

[ ៧ ] ធម៌មិនមែនជាកុសល អាស្រ័យនូវធម៌ ជាអកុសល ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ធម៌មិនមែនជាអព្យាកតៈ អាស្រ័យនូវធម៌ ជាអកុសល ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ធម៌មិនមែនជា

កុសលក្តី មិនមែនជាអព្យាកតៈក្តី អាស្រ័យនូវធម៌ ជាអកុសល ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ មានវារៈ ៣ ។

[ ៨ ] ធម៌មិនមែនជាកុសល អាស្រ័យនូវធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ធម៌មិនមែនជាអកុសល អាស្រ័យនូវធម៌ជាអព្យាកតៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ធម៌មិនមែនជាកុសលក្តី មិនមែនជាអកុសលក្តី អាស្រ័យនូវធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ មានវារៈ ៣ ។

[ ៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ១៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៩ ។

[ ១០ ] ធម៌មិនមែនជាកុសល អាស្រ័យនូវធម៌ ជាអកុសល ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ធម៌មិនមែនជាអព្យាកតៈ អាស្រ័យនូវធម៌ជាអកុសល ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ធម៌មិនមែនជាកុសលក្តី មិនមែនជាអព្យាកតៈក្តី អាស្រ័យនូវធម៌ ជាអកុសល ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌មិនមែនជាកុសល អាស្រ័យនូវធម៌ជាអព្យាកតៈ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ធម៌មិនមែនជាអកុសល អាស្រ័យនូវធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ធម៌មិនមែនជាកុសលក្តី មិនមែនជាអកុសលក្តី អាស្រ័យនូវធម៌ជាអព្យាកតៈ

ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ មានវារៈ ៣ ។

[ ១១ ] ធម៌មិនមែនជាកុសល អាស្រ័យនូវធម៌ ជាកុសល ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ ធម៌មិនមែនជាអកុសល អាស្រ័យនូវធម៌ជាកុសល ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ ធម៌មិនមែនជាកុសលក្តី មិនមែនជាអកុសលក្តី អាស្រ័យនូវធម៌ ជាកុសល ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ ។ ធម៌មិនមែនជាអកុសល អាស្រ័យនូវធម៌ជាអកុសល ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ ធម៌មិនមែនជាកុសល អាស្រ័យនូវធម៌ ជាអកុសល ទើបកើតឡើង ព្រោះនអារម្ម-ណប្បច្ច័យ ធម៌មិនមែនជាកុសលក្តី ធម៌មិនមែនជាអកុសលក្តី អាស្រ័យនូវធម៌ជាអកុសល ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ ។

[ ១២ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៦ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ១៥ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១៩ ក្នុងនោវិគតប្បច្ច័យ មានវារៈ ១៥ ។

បច្ចនីយៈ បណ្ឌិតគប្បីឲ្យពិស្តារ ទាំងសហជាតវារៈក្តី បណ្ឌិតគប្បីឲ្យពិស្តារ ទាំងបច្ចយវារៈក្តី បណ្ឌិតក៏គប្បីឲ្យពិស្តារ ។

[ ១៣ ] ចំណែកខាងបច្ចយវារៈ ក្នុងហេតុប្បច្ច័យ មានវារៈ ២៦ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១៨ ក្នុងអវិគតប្បច្ច័យ មានវារៈ ២៦ ។

និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[ ១៤ ] ធម៌ជាកុសល ជាបច្ច័យនៃធម៌ មិនមែនជាកុសល ដោយហេតុប្បច្ច័យ ធម៌ជាកុសល ជាបច្ច័យនៃធម៌ មិនមែនជាអព្យាកតៈ ដោយហេតុប្បច្ច័យ ធម៌ជាកុសល ជាបច្ច័យនៃធម៌ មិនមែនជាកុសលផង មិនមែនជាអព្យាកតៈផង ដោយហេតុប្បច្ច័យ ធម៌ជាកុសល ជាបច្ច័យនៃធម៌ មិនមែនជាកុសលផង មិនមែនជាអកុសលផង ដោយហេតុប្បច្ច័យ មានវារៈ ៥ ។

